# មគ្គុទ្ទេសក៍
# សេចក្តីថ្លែងទំនាក់ទំនងគ្រួសារ



រៀបរៀងដោយអង្គការសហគមន៍ឥន្ទធនូកម្ពុជា

បោះពុម្ពលើកទី២ ឆ្នាំ២០២០

# សន្ទានុក្រម

- **កិច្ចសន្យា** ៖ កិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈ ត្រូវគ្នាព្រមបង្កើតកែប្រែ ឬរំលត់កាតព្វកិច្ច។[1]
- **កតិកាសញ្ញា** ៖ ជាកិច្ចព្រមព្រៀងមួយដែលត្រូវបានធ្វើឡើងរវាងភាគីពីរ ឬច្រើន ឬរវាងរដ្ឋនិងរដ្ឋ ទាំងផ្លូវការ ទាំងមិនផ្លូវការ ដើម្បីធ្វើអ្វីមួយរួមគ្នាក្នុងគោលបំណងបម្រើផលប្រយោជន៍រវាងគ្នាទៅវិញទៅមក។ [2]
- **ក្រមរដ្ឋប្បវេណី** ៖ ក្រមនេះបញ្ញត្តអំពីគោលការណ៍ទូទៅ ដែលទាក់ទងនឹងទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី។ បញ្ញត្តិនៃក្រមរដ្ឋប្បវេណីនេះត្រូវយកមកអនុវត្តចំពោះទំនាក់ទំនងទ្រព្យសម្បត្តិ និងទំនាក់ទំនងញាតិ លើកលែងតែមានកំណត់ផ្សេងៗនៅក្នុងច្បាប់ពិសេស។[1]
- **កាតព្វកិច្ច ឬករណីយកិច្ច** ៖ ១- ការងារដែលត្រូវតែធ្វើ[3]។ ២- ចំណងតាមផ្លូវច្បាប់ដែលបង្ខំឱ្យត្រូវតែធ្វើ[4]។
- **គត្តិយុត្ត** ៖ ១-តាមគន្លងច្បាប់ ២-ដែលទាក់ទងនឹងច្បាប់ ដែលត្រឹមត្រូវតាមច្បាប់ (ក្រមរដ្ឋប្បវេណី, ២០០៧)។
- **ឆន្ទៈ** ៖ សេចក្តីប្រាថ្នា ឬបំណង ឬគំនិត ឬការយល់ព្រម។[3]
- **ទសវត្សរ៍** ៖ រយៈពេល១០ឆ្នាំ[3]។
- **ទ្រព្យសម្បត្តិរួម** ៖ ទ្រព្យសម្បត្តិទាំងឡាយ ដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដោយឡែក។[1]

---

[1] ព្រះរាជាណាចក្រកម្ពុជា. (២០០៧). *ក្រមរដ្ឋប្បវេណី*

2 កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងពិធីសារបន្ថែម ចូលជាធរមានតាមច្បាប់អន្តរជាតិនៅថ្ងៃទី៣ ខែមករា ឆ្នាំ ១៩៧៦.

[3] ជួន ណាត. *Buddhist Institution Dictionary*.កំណែទី២.១. ភ្នំពេញ: អ៊ុំ ចំរើន, ២០១១. កម្មវិធីកុំព្យូទ័រ

[4] ធយ អូន, ឥន យឿន, ងួន យ៉ាណា, អ៊ិត មល្លិកា, សៀន វិសាល. (២០១២). *សទ្ទានុក្រមពាក្យច្បាប់: ដកស្រង់ពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០១២. កម្ពុជា:* International Standard Books

- **នីតិភាព ៖** ១-គឺកម្រិតអាយុមួយ ដែលជនម្នាក់ត្រូវបានគេចាត់ទុកថា ត្រូវទទួលខុសត្រូវតាមផ្លូវច្បាប់ ចំពោះសកម្មភាពទាំងអស់របស់ខ្លួន ហើយត្រូវទទួលបាននូវសិទ្ធិស្របច្បាប់ ដែលប្រជាពលរដ្ឋទូទៅមាន [5] ។ ឧទាហរណ៍អាយុដែលត្រូវបានសិទ្ធិពេញលេញ ដើម្បីចុះកិច្ចសន្យា ធ្វើបណ្តាំមរតក និងការបោះឆ្នោត។ល។
- **នីតិជន** ៖ ១-បុគ្គលដែលមានអាយុគ្រប់តាមច្បាប់កំណត់ ហើយមានសមត្ថភាពឯករាជ្យខាងអំពើ។ ២- ជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។[1]
- **បទល្មើសព្រហ្មទណ្ឌ** ៖ អំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គម។ បទល្មើសត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់នៃបទល្មើសនោះ។[6]
- **បេក្ខភាព** ៖ លក្ខណៈសម្បត្តិនៃអ្នកដែលចង់បាននូវមុខតំណែង ការងារ ឬឋានន្តរផ្សេងៗ ដូចជាអ្នកប្រឡងប្រជែងដណ្តើមយកមុខតំណែងស្មៀន អ្នកតំណាងរាស្ត្រជាដើម។
- **មគ្គុទ្ទេសក៍** ៖ អ្នកណែនាំផ្លូវ។
- **មន្ត្រីអត្រានុកូលដ្ឋាន** ៖ មន្ត្រីដែលបម្រើការកត់ត្រា រក្សាទុកនូវឯកសារផ្លូវការ ដូចជាសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណភាព(ទស្សនាវដ្តីអាន)[7]។
- **សិទ្ធិស៊ីវិល ឬសិទ្ធិពលរដ្ឋ** ៖ សិទ្ធិដែលមិនមែនជាសិទ្ធិនយោបាយរបស់ពលរដ្ឋទាំងអស់ ជាពិសេសសិទ្ធិទាំងឡាយដែលទាក់ទងនឹងសេរីភាពផ្ទាល់ខ្លួន [5]។
- **សន្ធិសញ្ញា** ៖ កិច្ចព្រមព្រៀងអន្តរជាតិ ដែលធ្វើឡើងជាលាយលក្ខណ៍អក្សររវាងរដ្ឋនិងរដ្ឋ រវាងរដ្ឋនិងអង្គការអន្តរជាតិ ឬរវាងអង្គការអន្តរជាតិ និងអង្គការអន្តរជាតិហើយស្ថិតនៅក្រោមការគ្រប់គ្រង នៃនីតិអន្តរជាតិសាធារណៈ ទោះបីជាកិច្ចព្រមព្រៀងនោះមានឈ្មោះជាអ្វីក៏ដោយ (ធម្មនុញ្ញ សន្ធិសញ្ញា អនុសញ្ញា កតិកាសញ្ញា...) ដើម្បីបង្កើតអានុភាពគតិយុត្ត ។[1]
- **អភិរក្ស** ៖ ការរក្សាដោយប្រុងប្រយ័ត្ន[3]។

---

[5] គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា. *វចនានុក្រមពាក្យច្បាប់អង់គ្លេស-ខ្មែរ និងខ្មែរ-អង់គ្លេស.* ភ្នំពេញ:គណៈមេធាវីអាណត្តិទី៧, គ្មានកាលបរិច្ឆេទ .

[6] ក្រមព្រហ្មទណ្ឌ ២០០៩

[7] ទស្សនាវដ្តីអាន. (២០១២). *វចនានុក្រមអានខ្មែរ.* ដកស្រង់ពី http://dict.antkh.com

- **អត្រានុកូលដ្ឋាន ៖** ចំណាងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងឋានៈនៅក្នុងគ្រួសារហើយដែលបង្កើតឱ្យមានសិទ្ធិ និងករណីយកិច្ច។ ឧទាហរណ៍ ៖ លិខិតអត្រានុកូលដ្ឋានរួមមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និង សំបុត្រមរណភាព។[1]
- **អ្នកស្រឡាញ់ភេទដូចគ្នា ៖** មានដូចជា ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អន្តរភេទ អ្នកប្តូរយេនឌ័រ និងអ្នកមិនកំណត់អត្តសញ្ញាណយេនឌ័រខ្លួនឯង។

# ១. សេចក្តីផ្តើម

មគ្គុទេសក៍សេចក្តីថ្លែងទំនាក់ទំនងគ្រួសារ គឺជាឯកសារណែនាំពីអត្ថន័យ ការប្រើប្រាស់ និងលក្ខន្តិកៈនានានៃទម្រង់បែបកិច្ចសន្យាឯកជន ដើម្បីជួយសម្រួលទៅដល់អ្នកពាក់ព័ន្ធរួមមាន ដៃគូអ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកសម្របសម្រួលនៃការចុះសេចក្តីថ្លែងទំនាក់ទំនងគ្រួសារ ដែលមានដូចជាអាជ្ញាធរមូលដ្ឋាន សមាជិកសកម្មនិងបុគ្គលិករបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជាជាដើម។ នេះជាការបោះពុម្ពលើកទី២ ដោយការបោះពុម្ពលើកទី១ គឺនៅក្នុងឆ្នាំ២០១៦។

# ២. ប្រវត្តិនៃអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា

វត្តមានរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជាគឺមានយូរមកហើយបើទោះបីជាមិនសូវមានឯកសារប្រវត្តិសាស្ត្របញ្ជាក់ក៏ដោយ។ ជាក់ស្តែងនៅក្នុងកំណត់ហេតុរបស់ ជីវ តាក្វាន់ ក្នុងសម័យអង្គរ ឆ្នាំ១២៩៦ «មានបុរស "ដែលលក្ខណៈដូចស្ត្រី" នៅក្នុងប្រទេសបានដើរលេងនៅក្នុងផ្សារក្នុងចំណោមប្រជាជនជាច្រើន[8] [...]» ។



[8] សៀវភៅកំណត់ត្រានៃកម្ពុជា៖ទឹកដីនិងប្រជាជនកម្ពុជា ( A Record of Cambodia: The Land and Its People ) ដោយ ជូ តាក្វាន់ 1296 និងមានការប្រែសម្រួលជាភាសាអង់គ្លេសនៅឆ្នាំ 2007

តាមរយៈសៀវភៅរូបថតដែលមានចំណងជើងថា «ធម្មតា ២»[9] ក៏បានលើកឡើងពីសាច់រឿងពិតរបស់ដៃគូស្នេហាស្រ្តីស្រឡាញ់ស្រ្តីចំនួន ៣គូ ដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧០-១៩៧៥ (របបខ្មែរក្រហម)ផងដែរ ។មកដល់សព្វថ្ងៃ ដៃគូអ្នកស្រឡាញ់ភេទដូចគ្នា មានចម្រុះវ័យប្រមាណជាង១០០០គូ តាមរយៈការងារចងក្រងរបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជា ។ វាបង្ហាញឱ្យឃើញថា បើទោះបីជាផ្លូវច្បាប់ និងសង្គមមិនទាន់ទទួលស្គាល់ អ្នកស្រឡាញ់ភេទដូចគ្នាពេញលេញនៅឡើយ ប៉ុន្តែពួកគេបានកសាងជាក្រុមគ្រួសារ បំពេញកាតព្វកិច្ច និងតម្រូវការ ដើម្បីទទួលបានសុភមង្គលរួចមកហើយ។

## ៣. គតិយុត្តនៃអ្នកស្រឡាញ់ភេទដូចគ្នា



មានសំណួរជាច្រើនតែងតែចោទឡើងថា តើនៅកម្ពុជាមានច្បាប់ស្តីពីក្រុមអ្នកស្រឡាញ់ភេទដូចគ្នាឬទេ? ចម្លើយពីអ្នកសិក្សាច្បាប់ រួមទាំងមេធាវីផងដែរ បានផ្តល់នូវចម្លើយយ៉ាងខ្លីថា "**មិនមានទេ**"។ នៅក្នុងក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ និងរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ បានចែងអំពី «បុរស និងស្រ្តីមានសិទ្ធិស្មើគ្នាក្នុងគ្រប់ វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ។» ទន្ទឹមនឹងនោះ ប្រទេសកម្ពុជាក៏មិនមានការដាក់ទោសទណ្ឌ ឬហាមឃាត់ចំពោះអត្តសញ្ញាណ និងទំនាក់ទំនងស្នេហារបស់អ្នក

[9] ធម្មតា II ដោយវុធ លីណូ និង ផលិតដោយសហគមន៍ឥន្ទធនូកម្ពុជា(រ៉ាក់) ឆ្នាំ២០១៣

ស្រឡាញ់ភេទដូចគ្នាដែរ។ ផ្ទុយទៅវិញ ប្រទេសកម្ពុជាមានបរិយាកាសអំណោយផលចំពោះសិទ្ធិមនុស្សជាទូទៅរបស់សហគមន៍នេះ។

ដោយហេតុថាកម្ពុជាជារដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ ហើយបានទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ ដូចនេះប្រទេសកម្ពុជាបានប្តេជាចិត្តក្នុងការពារ លើកស្ទួយ និងមានវិធានការ ដើម្បីធានានូវការគោរពសិទ្ធិមនុស្ស ដែលការប្តេជ្ញាចិត្តនេះក៏បានចែងក្នុងមាត្រា៣១ នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា។ បន្ថែមទៅលើនោះ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា ឆ្នាំ២០០៧ [10] បញ្ជាក់ឡើងវិញថា សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលត្រូវបានផ្តល់សច្ចាប័នដោយព្រះរាជាណាចក្រកម្ពុជា អាចអនុវត្តន៍ដោយផ្ទាល់នៅតុលាការកម្ពុជា។

ម្យ៉ាងទៀត វាមានន័យថា មាត្រាខាងក្រោមនៃច្បាប់អន្តរជាតិ អនុវត្តន៍ទៅលើពលរដ្ឋកម្ពុជាដែលជា អ្នកស្រឡាញ់ភេទដូចគ្នា៖

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ជាពិសេសមាត្រា ១ ២ ៧ ១២ និង ១៦
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ជាពិសេស មាត្រា២(១) ១៧ ២៣ និង ២៦
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ជាពិសេស មាត្រា១ ២ ១៥ និង ១៦

*មាត្រា ២៦ នៃសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន ឆ្នាំ២០១២* ក៏បានអះអាងឡើងវិញដែរថា ***«មនុស្សទាំងអស់គួរតែមានភាពស្មើគ្នាចំពោះមុខច្បាប់ ហើយការរើសអើងគឺខុសច្បាប់ ។»***

*គោលការណ៍ យ៉កយ៉ាកាតា ឆ្នាំ២០០៦* បានផ្តល់អោយនូវការណែនាំពីការគោរពនៃការអនុវត្តទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលផ្តោតទៅលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ។

[10] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ លេខ ០៩២/០០៣/២០០៧ ទាក់ទង នឹងការអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដោយតុលាការនៅក្នុងប្រទេសកម្ពុជា

បន្ថែមទៅលើនោះ កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ កម្ពុជាបានទទួលយកនូវអនុសាសន៍ទាំង៩ ចេញពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ (យូ.ភី.អ)[11] ជុំទី៣ ដែលទាក់ទងនឹងសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នារួមមាន *(១) បង្កើតគោលនយោបាយស្តីពីការប្រឆាំងនឹងការរើសអើងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។ (២) វិសោធនកម្មមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតឱ្យមានអាពាហ៍ពិពាហ៍ស្របច្បាប់សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា និង(៣)តាក់តែងច្បាប់ស្តីពី ការទទួលស្គាល់អត្តសញ្ញាណយេនឌ័រ របស់បុគ្គល ដែលជាអ្នកស្រឡាញ់ភេទដូចគ្នា ឲ្យស្របទៅនឹងអាទិភាពតម្រូវការដូចបានរៀបរាប់ខាងលើ។* ការទទួលយកអនុសាសន៍ទាំងនេះបានបង្ហាញនូវឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងស្ថានភាពសិទ្ធិមនុស្សរបស់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជា។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី**
**ការទទួលយកអនុសាសន៍នៃកិច្ចប្រជុំពិនិត្យជាសកលតាមកាលកំណត់ (UPR) ជុំទី៣ សម្រាប់កម្ពុជា នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស**
**កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩**

ក្នុងកិច្ចប្រជុំលើកទី៣២នៃ UPR Working Group របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ស្តីពីយន្តការពិនិត្យជាសកលតាមកាលកំណត់ (UPR) ជុំទី៣សម្រាប់កម្ពុជា នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ កន្លងមក កម្ពុជាទទួលបាននូវអនុសាសន៍សរុបចំនួន ១៩៨ ដែលផ្តល់ដោយរដ្ឋចំនួន៧៣ជាសមាជិកអង្គការសហប្រជាជាតិ។ ក្នុងចំណោមអនុសាសន៍ទាំងនោះ អនុសាសន៍មួយចំនួនផ្តោតលើការកោតសរសើរ និងស្វាគមន៍ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល




*ប្រភពរូបភាព៖ ទំព័រហ្វេសប៊ុកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។*

ជាចុងក្រោយ អគ្គលេខាធិការអង្គការសហប្រជាជាតិ លោក បាន គីមូន បានមានប្រសាសន៍ថា "*សិទ្ធិមនុស្សគឺសម្រាប់មនុស្សគ្រប់គ្នា មិនថាអ្នកជាអ្នកណា ឬអ្នកនោះស្រឡាញ់អ្នកណាឡើយ។* " ដូចនេះអ្នកស្រឡាញ់ភេទដូចគ្នាក៏មានសិទ្ធិទទួលការអប់រំ សិទ្ធិរស់រានមានជីវិត សិទ្ធិជៀសផុតពីការរើសអើង សិទ្ធិជ្រើស

---

[11] ការត្រួតពិនិត្យជាសកលតាមកាលកំណត់ (យូ.ភី.អ) ជុំទី៣ គឺជាយន្តការមួយរបស់អង្គការសហប្រជាជាតិអនុវត្តតាមរយៈការត្រួតពិនិត្យ ទៅលើការគោរពប្រតិបត្តិ ទៅតាមកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋនីមួយៗ ដែលជាសមាជិកអង្គការសហប្រជាជាតិ ក្នុងការផ្តល់យោបល់ និងបំពេញបន្ថែម រវាងរដ្ឋ និងរដ្ឋ ដើម្បីឱ្យស្ថានភាពសិទ្ធិមនុស្សមានភាពប្រសើរឡើង និងដើម្បីបំពេញកាតព្វកិច្ចសិទ្ធិមនុស្ស នៅក្នុងប្រទេសរបស់ខ្លួន។

ជើសដៃគូ ឬគូស្រករ។ល។ ដែលសិទ្ធិទាំងឡាយនោះត្រូវបានអនុវត្ត ដើម្បីគោរពនូវភាពថ្លៃថ្នូរនៃមនុស្សជាតិ ដោយមិនប្រកាន់វណ្ណៈ ពូជសាសន៍ សាសនា នយោបាយ ភេទ និងនិន្នាការផ្លូវភេទឡើយ។

## ៤. ឧបសគ្គនៃអ្នកស្រឡាញ់ភេទដូចគ្នា

( *ឈ្មោះអ្នកសរសេរដាក់ឱ្យ ដើម្បីរក្សាការសម្ងាត់ពីអត្តសញ្ញាណរបស់បុគ្គល )

*ករណីសិក្សាទី១*

*ឌី* និង ដា* ជាដៃគូស្ត្រីស្រឡាញ់ស្ត្រី ដែលបានរួមរស់នៅជាមួយគ្នា មើលថែទាំគ្នាទៅវិញទៅមក អស់រយៈពេល២៦ឆ្នាំមកហើយ។ នៅឆ្នាំ២០០០ ពួកគាត់ទាំងពីរនាក់បានសុំកូនស្រីម្នាក់មកចិញ្ចឹមបីបាច់។ ពួកគាត់បានទៅចុះសំបុត្រកំណើតកូនស្រីនោះនៅសាលាឃុំ ដោយមន្ត្រីអត្រានុកូលដ្ឋានបានយល់ព្រម ដោយដាក់អ្នកទាំងពីរ ម្នាក់ជាឪពុក ម្នាក់ទៀតជាម្តាយ។ ប៉ុន្មានឆ្នាំក្រោយមក ឌី ក៏ទៅធ្វើសៀវភៅគ្រួសារ ព្រោះយល់ថារស់នៅជាមួយគ្នាយូរឆ្នាំហើយ ព្រមទាំងមានកូននៅក្នុងបន្ទុកទៀត ដូច្នេះវាសំខាន់ដែលមានឯកសារផ្លូវច្បាប់ ដើម្បីបញ្ជាក់ពីទំនាក់ទំនងសាច់ញាតិនៃគ្រួសារនេះ។ ឌី និងដា បានទៅរកមន្ត្រីអត្រានុកូលដ្ឋាន ប៉ុន្តែមន្ត្រីនគរបាលប៉ុស្តិ៍បដិសេធមិនអាចសរសេរបញ្ជាក់ថា ឌី និងដា មានទំនាក់ទំនងជាឪពុកម្តាយ ដោយសារពួកគាត់មានភេទស្រីពីកំណើតដូចគ្នា។ អ្នកទាំងពីរមានការព្រួយបារម្ភទៅលើសំបុត្រកំណើតកូនរបស់គាត់ ដែលមានលក្ខណៈខុសគ្នាពីសៀវភៅគ្រួសារបែបនេះ ដោយហេតុអាចបង្កផលវិបាកនាពេលអនាគត នៅពេលកូនគាត់ត្រូវដាក់ពាក្យស្នើសុំធ្វើអត្តសញ្ញាណបណ្ណ ដាក់ពាក្យធ្វើការងារ និងទទួលមរតកផងដែរ។*

***ករណីសិក្សាទី២***

***វ៉ាន់* ជាអ្នកផ្លាស់ប្តូរយេនឌ័រពីស្រីទៅប្រុស មានទំនាក់ទំនងស្នេហាជាមួយ ស្រីស* អស់រយៈពេល២ឆ្នាំ។ នៅពេលឪពុកម្តាយស្រីសបានដឹងពីទំនាក់ទំនងនេះ ពួកគាត់មានបំណងចង់ផ្តាច់ទំនាក់ទំនងស្នេហារវាងអ្នកទាំងពីរ ដោយចោទវ៉ាន់ពីបទជួញដូរមនុស្ស និង រួមភេទជាមួយអនីតិជន ដែលសំដៅទៅលើការរួមភេទជាមួយកូនស្រីរបស់គាត់ដែលបានចូលបម្រើការងារនៅសហគ្រាសឯកជន បើទោះជាអ្នកទាំងពីរបានស្រឡាញ់គ្នាដោយស្ម័គ្រស្មោះ មិនមានអ្នកណាបង្ខិតបង្ខំអ្នកណាឡើយ។ ជាលទ្ធផល វ៉ាន់ត្រូវជាប់នៅក្នុងពន្ធនាគារអស់ជាច្រើនខែ មុនពេលទទួលបានការកាត់ក្តីដោយយុត្តិធម៌។***

ទាំងនេះគឺជាសាច់រឿង ដែលបង្ហាញពីឧបសគ្គកើតឡើងចំពោះអ្នកស្រឡាញ់ភេទដូចគ្នាទាំងក្នុងបរិបទសង្គម និងផ្លូវច្បាប់ នៅប្រទេសកម្ពុជា។ ការស្រាវជ្រាវរបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជាស្តីពី «ការយល់ឃើញ អាកប្បកិរិយា និងឥរិយាបថចំពោះអ្នកស្រឡាញ់ភេទដូចគ្នា ក្នុងប្រទេសកម្ពុជា» ក្នុងឆ្នាំ២០១៥ បានរកឃើញថា ៨០% នៃសាធារណជន និងអ្នកស្រឡាញ់ភេទដូចគ្នាចំនួន ១៥៦៣នាក់ យល់ថាការរើសអើងគឺជាបញ្ហាចម្បង បំផុតរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ។ ការរិះគន់ សើចចំអក មាក់ងាយ ការមិនផ្តល់សិទ្ធិក្នុងការជ្រើសរើសដៃគូ ការមើលរំលង និងការផាត់ចេញ[12] នៃដៃគូអ្នកស្រឡាញ់ភេទដូចគ្នាចេះតែកើតមានឡើងគួរឲ្យកត់សម្គាល់។ ជាក់ស្តែងដោយសារឧបសគ្គខាងលើនេះហើយ រារាំងចំពោះការហ៊ានចេញមុខជាចំហរ ទៅកាន់គ្រួសារ និងសហគមន៍ជុំវិញ ដែលជាហេតុធ្វើឱ្យសហគមន៍អ្នកស្រឡាញ់កាន់តែក្លាយជាក្រុមងាយរង គ្រោះ។

ក្នុងការស្រាវជ្រាវឆ្នាំ ២០១៥ ដដែលបានបង្ហាញពីការយល់ស្របរបស់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នានិងសាធារណជនចំពោះតម្រូវការអាទិភាពរបស់អ្នកស្រឡាញ់ភេទដូចគ្នា ដែលក្នុងនោះរួមមាន៖

១) ការសុំកូនពេញលេញសម្រាប់គ្រួសារដែលជាអ្នកស្រឡាញ់ភេទដូចគ្នា

២) អាពាហ៍ពិពាហ៍ស្របច្បាប់

៣) ការទទួលស្គាល់ អត្តសញ្ញាណយេនឌ័ររបស់អ្នកប្តូរយេនឌ័រ នៅក្នុងឯកសារបញ្ជាក់អត្តសញ្ញាណរបស់ពលរដ្ឋ ឧទាហរណ៍ សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ។ល។

# ៥. ប្រវត្តិនៃសេចក្តីថ្លែងទំនាក់ទំនងគ្រួសារ

សេចក្តីថ្លែងទំនាក់ទំនងគ្រួសារ គឺជាគំនិតផ្តួចផ្តើមរួមពីសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា អាជ្ញាធរមូលដ្ឋាន មេធាវី អ្នកច្បាប់ជាតិ និងអន្តរជាតិ។ សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ដែលជាសមាជិកនៃសហគមន៍ឥន្ទធនូកម្ពុជា តែងតែជួបជុំគ្នាជាពិសេសតាមរយៈកម្មវិធីទិវាសប្តាហ៍មោទនភាព និងទិវាសិទ្ធិមនុស្សអន្តរជាតិ ដើម្បីជជែកពិភាក្សាទៅលើភាពលំបាក ឬឧបសគ្គដែលខ្លួនជួបប្រទះនិងស្នើសុំគំនិតយោបល់ស្វែងរកដំណោះស្រាយពីអ្នកពាក់ព័ន្ធដែលមានដូចជា អាជ្ញាធរមូលដ្ឋាន មេធាវី អ្នកច្បាប់ជាតិនិងអន្តរជាតិជាដើម។ ជាលទ្ធផល ទម្រង់កិច្ចសន្យាដែលហៅថាសេចក្តីថ្លែងទំនាក់ទំនងគ្រួសារត្រូវបានព្រាងឡើង និងឆ្លងកាត់ការពិគ្រោះយោបល់ចំនួន ៣ដង និងសាកល្បងបំពេញទម្រង់ ហើយបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅឆ្នាំ២០១៦។

---

[12] បេកកំហើញនៅក្នុងរបាយការណ៍អំពើហិង្សាគ្រួសារប្រឆាំងនឹងស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស នៅក្នុងប្រទេសកម្ពុជាឆ្នាំ២០១៩ នៃអង្គការសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់) https://bit.ly/2YuaqNY

### *តើអ្វីជាសេចក្តីថ្លែងទំនាក់ទំនងគ្រួសារ?*

សេចក្តីថ្លែងទំនាក់ទំនងគ្រួសារគឺជាទម្រង់កិច្ចសន្យាស្នេហាដែលការពារផ្នែកច្បាប់ សម្រាប់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នា ដែលមានបំណងរស់នៅជាមួយគ្នាជាគ្រួសារ ។ ទម្រង់នេះជាយន្តការឆ្លើយតបបណ្តោះអាសន្ននៅពេលដែលប្រទេសកម្ពុជាមិនទាន់មានច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នានៅឡើយ។

## ៦. សារៈសំខាន់នៃការមានសេចក្តីថ្លែងទំនាក់ទំនងគ្រួសារ

ដោយហេតុថា ច្បាប់ក្នុងស្រុកមិនបានចែងអំពីទំនាក់ទំនងនៃអ្នកស្រឡាញ់ភេទដូចគ្នា ដូចនេះទំនាក់ទំនងនៃអ្នកស្រឡាញ់ភេទដូចគ្នាត្រូវបានបដិសេធដោយមន្ត្រីអត្រានុកូលដ្ឋាន ក្នុងការចុះបញ្ជីនៃទំនាក់ទំនងគ្រួសារជាផ្លូវការ ក្នុងលិខិតអាពាហ៍ពិពាហ៍ ដូចទៅនឹងអ្នកស្រឡាញ់ភេទផ្ទុយគ្នា។

ដោយសារតែភាពរស់នៅជាលក្ខណៈគ្រួសារ ដូចជាស្វាមីភរិយាចាំបាច់ត្រូវមានឯកសារណាមួយ ក្នុងការបង្ហាញនូវទំនាក់ទំនងគ្រួសារ ដែលវាមានសារៈសំខាន់មួយចំនួនដូចខាងក្រោម ៖

ក. ផ្តល់ឱ្យគូស្នេហាភេទដូចគ្នា មានភស្តុតាងផ្លូវការ អំពីទំនាក់ទំនងពិតនេះ។
ខ. ពង្រឹងនូវប្រសិទ្ធិភាពនៃការដឹងឮ និងទទួលយកពីសំណាក់គ្រួសារ និងសហគមន៍ អំពីទំនាក់ទំនងនៃដៃគូភេទដូចគ្នា។

គ. បញ្ជាក់ពីកាតព្វកិច្ចចិញ្ចឹមកូនបីបាច់ និងថែរក្សាកូន ទាំងកូនបង្កើត និងកូនចិញ្ចឹម។

ឃ. បង្ហាញនូវការរស់នៅក្នុងសង្គមដោយស្មើភាព គ្មានការរើសអើង និងចេញមុខជាសាធារណៈ ។
ង. រឹតចំណងនូវក្តីស្រឡាញ់ ដោយភក្តីភាពរវាងគូភាគី ព្រមទាំងកំណត់នូវកាតព្វកិច្ច និងករណីយកិច្ចចំពោះគ្នាទៅវិញទៅមក។

ច. បង្កើតជាភស្តុតាងអំពីទ្រព្យសម្បត្តិរួម ដែលរកបានក្នុងរយៈពេលរួមរស់ជាមួយគ្នា ដែលបានចុះនៅក្នុងទម្រង់សេចក្តីថ្លែងទំនាក់ទំនងគ្រួសារ។

ឆ. ការពារនឹងការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌផ្សេងៗមកលើភាគីណាមួយ នៃទំនាក់ទំនងគ្រួសារនេះ។

ជ. បញ្ជាក់ពីតម្រូវការចាំបាច់ផ្នែកច្បាប់ ជាពិសេសលទ្ធភាពនៃការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ និងក្រមរដ្ឋប្បវេណីដើម្បីទទួលស្គាល់ និងការពារសហព័ទ្ធ និងគ្រួសារអ្នកស្រឡាញ់ភេទដូចគ្នា។

# ៧. ការត្រៀមធ្វើសេចក្ដីថ្លែងទំនាក់ទំនងគ្រួសារ

## លក្ខខណ្ឌក្នុងការធ្វើសេចក្ដីថ្លែងទំនាក់ទំនងគ្រួសារ

- **នីតិភាព៖**សេចក្ដីថ្លែងទំនាក់ទំនងគ្រួសារអាចធ្វើទៅបាន លុះត្រាតែភាគីទាំងពីរជានីតិជន (មានអាយុចាប់ពី១៨ឆ្នាំឡើង)។ ដូច្នេះបុគ្គលដែលធ្វើសេចក្ដីថ្លែងទំនាក់ទំនងគ្រួសារត្រូវមានអាយុ១៨ឆ្នាំឡើង ដោយយោងទៅតាមក្រមរដ្ឋប្បវេណី[13] ។

- **គោលការណ៍ស្ម័គ្រចិត្ត៖** លើសពីនេះ ការធ្វើសេចក្ដីថ្លែងទំនាក់ទំនងគ្រួសារគឺផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត និងព្រមព្រៀងរវាងភាគីទាំងសងខាង ដើម្បីជៀសវាងការចោទប្រកាន់ ឬភាន់ច្រឡំផ្សេងៗ។

- **រយៈពេលនៃការត្រៀមខ្លួន៖** សេចក្ដីថ្លែងទំនាក់ទំនងគ្រួសារគឺជាលិខិតស្នាមផ្លូវការដែលមានតម្លៃគតិយុត្តស្មើនឹងកិច្ចសន្យាឯកជន។ ហេតុនេះ ការសម្រេចចិត្តក្នុងការធ្វើសេចក្ដីថ្លែងទំនាក់ទំនងគ្រួសារ ត្រូវបានលើកទឹកចិត្តឱ្យដៃគូគិតពីផលប៉ះពាល់មួយចំនួនដូចជា ការមិនទាន់ត្រៀមខ្លួនរួចរាល់ក្នុងការរួមរស់ជាមួយគ្នា និងទទួលខុសត្រូវរួមគ្នាក្នុងភាពជាគ្រួសារជាដើម។ ដូចនេះសេចក្ដីថ្លែងទំនាក់ទំនងគ្រួសារ បានកំណត់រយៈពេលរស់នៅជាមួយគ្នា*ចាប់ពី៣ឆ្នាំឡើង* ដែលជារយៈពេលសមស្របមួយក្នុងការបង្ហាញពី*ការរស់នៅជាប់លាប់ក្រោមដំបូលផ្ទះតែមួយ ចាប់ដៃគ្នាប្រកបមុខរបរចិញ្ចឹមជីវិត និងថែទាំគ្នាទៅវិញទៅមក*ដើម្បីឱ្យដៃគូអ្នកស្រឡាញ់ភេទដូចគ្នាអាចសិក្សាស្វែងយល់ពីគ្នាបានច្បាស់លាស់ ហើយមានទំនុកចិត្ត។ ក្រៅពីនេះ ប្រសិនបើដៃគូដែលរួមរស់ជាមួយគ្នាមានការទទួលស្គាល់ ឬដឹងឮ ពីសំណាក់ចាស់ទុំនៅក្នុងភូមិឃុំ បានរៀបចំពិធីសែនព្រេន ជប់លៀង អបអរ ឬរៀបការតាមប្រពៃណី ក៏កាន់តែប្រសើរ ពីព្រោះវាជាភស្តុតាងបន្ថែមនៃការដឹងឮពីទំនាក់ទំនងស្នេហា។

---

[13] យោងទៅតាមមាត្រា ១៧ ក្រមរដ្ឋប្បវេណិ  អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

ក្រមរដ្ឋប្បវេណី មាត្រា ៩៤៨ នីតិភាពនៃការរៀបអាពាហ៍ពិពាហ៍

## លក្ខន្តិកៈ (ការកំណត់)

- ### ឯកសារមួយក្នុងចំណោម៖

    - សំបុត្រកំណើត ឬអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន
    - សៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ការស្នាក់នៅបណ្តោះអាសន្ន

- ### សាក្សី ៖

    - ដៃគូត្រូវស្វែងរកសាក្សីចំនួន២នាក់ ដែលជាអ្នកដែលដឹងឮពីរយៈពេលនៃការរស់នៅ និងទំនាក់ទំនងស្នេហារបស់ភាគីទាំងពីរ។ គូភាគីទាំងសងខាងគួរមានការពិភាក្សាជាមួយសាច់ញាតិក្រុមគ្រួសារ (ប្រសិនបើរស់នៅជាមួយគ្រួសារ) ដើម្បីធ្វើជាសាក្សីក្នុងសេចក្តីថ្លែងទំនាក់ទំនងគ្រួសារ។

    - ភាគីទាំងសងខាងគួរពន្យល់សាក្សីដែលខ្លួនបានជ្រើសរើស អំពីតួនាទីរបស់សាក្សី គឺគ្រាន់តែអ្នករួមចំណែកដឹងឮ អំពីការចុះកិច្ចសន្យាទំនាក់ទំនងគ្រួសារនេះប៉ុណ្ណោះ។ សាក្សីមិនមានទំនួលខុសត្រូវផ្នែកច្បាប់ណាមួយ ដូចទៅនឹងភាគីដែលជាម្ចាស់កិច្ចសន្យានៃសេចក្តីថ្លែងទំនាក់ទំនងគ្រួសារឡើយ។

### ❖ សម្រាប់អ្នកសម្របសម្រួល

អ្នកសម្របសម្រួលអាចជាអាជ្ញាធរមូលដ្ឋាន និងសកម្មជនរបស់អង្គការ សមាគម ឬបណ្តាញសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។ មុនការចុះ អ្នកសម្របសម្រួលអាចជួយដៃគូរៀបចំដើម្បីប្រាកដថា លក្ខន្តិកៈ និងតម្រូវការឯកសារដែលបានរៀបរាប់ខាងលើ ត្រូវបានរៀបចំជាស្រេច។ ក្នុងនោះចំណុចសំខាន់គួរកត់សម្គាល់រួមមាន៖

- ឯកសារថតចម្លងរបស់គូភាគីដូចជា អត្តសញ្ញាណប័ណ្ណ និងសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ការស្នាក់នៅបណ្តោះអាសន្ន។
- ទម្រង់សេចក្តីថ្លែងទំនាក់ទំនងគ្រួសារ
- សាក្សីពីររូបដែលត្រូវមានវត្តមាននៅពេលចុះទម្រង់

# ៨. ការបំពេញទម្រង់សេចក្តីថ្លែងទំនាក់ទំនងគ្រួសារ

ទំព័រទី១ នៃសេចក្តីថ្លែងទំនាក់ទំនងគ្រួសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សេចក្តីថ្លែងទំនាក់ទំនងគ្រួសារ**

1

ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០២០

| | |
|---|---|
| ខេត្ត/ក្រុង | ស្វាយរៀង |
| ស្រុក/ខណ្ឌ | ស្វាយជ្រំ |
| ភូមិ/សង្កាត់ | ភូមិក្តុម្ពី ឃុំគោកព្រីង |

2

3

| ភាគី (ក) | | ភាគី (ខ) | |
|---|---|---|---|
| ឈ្មោះ | សុខ សេរី | ឈ្មោះ | ព្រំ សីហា |
| អាយុ | ១៩៨៣ | អាយុ | ១៩៨០ |
| អាសយដ្ឋាន | ភូមិក្តុម្ពី ឃុំគោកព្រីង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង | អាសយដ្ឋាន | ភូមិក្តុម្ពី ឃុំគោកព្រីង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង |
| មុខរបរ | កសិករ | មុខរបរ | គ្រូបង្រៀន |

***ក. អំពីទំនាក់ទំនងក្នុងគ្រួសារ***

*រយៈពេលនៃការរស់នៅជាមួយគ្នា ៖ ៧ ឆ្នាំ*

*បានធ្វើពិធីជួបជុំតាមប្រពៃណី៖ កាលពីថ្ងៃទី ១៧ ខែ ០៥ ឆ្នាំ ២០០៣* 4

*មានកូន-កូនចិញ្ចឹម៖ ✓ មាន គ្មាន។ ប្រសិនបើមាន សូមបំពេញលើទម្រង់ដោយឡែក។*

*យើងខ្ញុំទាំងពីរនាក់ដូចមានរាយនាមខាងលើ សូមប្រកាសថា៖ យើងខ្ញុំពិតជាស្រឡាញ់គ្នា ព្រមទាំងបានបង្កើតនូវទំនាក់ទំនងគ្រួសារដូចជាប្តី និងប្រពន្ធ ដោយគោរព ថែរក្សា និងចែករំលែកនូវការទទួលខុសត្រូវរវាងគ្នា និងគ្នាទៅវិញទៅមក។*

*យើងខ្ញុំសូមប្រកាសជាផ្លូវការ ក្នុងឯកសារនេះថា៖ ការប្តេជ្ញាចិត្តនៃសេចក្តីស្រឡាញ់យើងខ្ញុំទាំងពីរនាក់ ពិតជាមានសារៈសំខាន់ណាស់ក្នុងការជីវិត និងទទួលស្គាល់ថាខ្ញុំឈ្មោះ សុខ សេរី* 5 *និងខ្ញុំឈ្មោះ ព្រំ សីហា បានរួមរស់នៅជាមួយគ្នាជាគ្រួសារ ដូចជាប្តី និងប្រពន្ធ។*

*គូភាគីខាងលើបានបង្ហាញនូវឆន្ទៈរបស់ខ្លួនដោយសេរី និងពេញចិត្ត។ ភាគីទាំងពីរជានិងទទួលខុសត្រូវចំពោះសេចក្តីថ្លែងរបស់ខ្លួនទាំងស្រុង។ សេចក្តីថ្លែងនេះមិនមែនជាទស្សនៈ និងការទទួលខុសត្រូវរបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជាឡើយ។ លិខិតនេះផ្តល់ឲ្យសាមីខ្លួនយកទៅប្រើប្រាស់តាមដែលអាចប្រើប្រាស់បាន។* 6

*ទំព័រ១នៃ៣*

*(សូមមើលរូបឧទាហរណ៍និងលេខតំណាងតាមចន្លោះបំពេញ)*

1. និង 2.សូមអ្នក**បំពេញ** ***ថ្ងៃ ខែ និងឆ្នាំ*** និង ***ទីតាំង***ដែលភាគីទាំងពីរផ្តិតមេដៃក្នុងសេចក្តីថ្លែងទំនាក់ទំនងគ្រួសារ។

**3.** ***ភាគី(ក) និងភាគី(ខ)***៖ នេះជាឈ្មោះគូភាគីសហព័ទ្ធ ដែលបានរួមរស់ជាមួយគ្នា ដូចជាប្តី និងប្រពន្ធ។ ត្រង់ចំណុចនេះមិនបានដាក់ ' ភេទ ' ទេ ដោយហេតុថា អាពាហ៍ពិពាហ៍ ឬទំនាក់ទំនងគ្រួសារ ឬសហព័ទ្ធ ឬប្តីប្រពន្ធ មិនគួរមានការរើសអើងលើភេទរបស់បុគ្គលឡើយ។

-***អាយុ***៖ សូមអ្នកដាក់ ថ្ងៃ ខែ ឆ្នាំកំណើត ឲ្យពេញលេញ ដូចដែលបានចុះក្នុងសៀវភៅស្នាក់នៅ ឬអត្តសញ្ញាណប័ណ្ណ។

-***អាសយដ្ឋាន***៖ សូមអ្នកដាក់អាសយដ្ឋានបច្ចុប្បន្ន ដែលគាត់កំពុងរស់នៅជាមួយគ្នា។ ជាទូទៅសូមអ្នកចម្លងចេញពីសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ការស្នាក់នៅបណ្តោះអាសន្ន។

**4.** ***រយៈពេលនៃការរស់នៅជាមួយគ្នា***៖ ទីនេះសូមអ្នកសរសេរត្រឹមតែចំនួនឆ្នាំ ដែលគូភាគីបានរស់នៅជាមួយគ្នា។

-***បានធ្វើពិធីជួបជុំតាមប្រពៃណី***៖ សូមបំពេញកាលបរិច្ឆេទនៃកម្មវិធី សែនព្រេន ការចូលព្រះវិហារ ឬនិមន្តព្រះសង្ឃសូត្រមន្តផ្តល់ជ័យមង្គលជាដើម ដែលសបញ្ជាក់អំពីការប្តេជាចិត្តរួមរស់នៅជាមួយគ្នាជាដៃគូជីវិត។ ចំនុចនេះអាចរាប់បញ្ចូលទាំងការរៀបអាពាហ៍ពិពាហ៍ទៅតាមប្រពៃណីផងដែរ។ ប្រសិនបើគូភាគីមិនចាំពីថ្ងៃ និងខែទេ នោះគេអាចដាក់តែឆ្នាំក៏បានដែរ។

**5.*ក្នុងចំណុចកូន - កូនចិញ្ចឹម***៖ សូមគូសក្នុងប្រអប់មាន ឬ គ្មាន តាមស្ថានភាពជាក់ស្តែងរបស់ដៃគូ។ សូមរាប់តែកូនដែលស្ថិតនៅក្នុងបន្ទុករបស់ភាគីទាំងពីរ បូករួមកូនដែលពេញវ័យផងដែរ។ តាមការអនុវត្តជាក់ស្តែងបុគ្គលអ្នកស្រឡាញ់ភេទដូចគ្នាមួយចំនួនអាចមានកូនបង្កើតពីការរៀបចំ ឬទំនាក់ទំនងណាមួយ និងកូនចិញ្ចឹមរួមនៃដៃគូឬភាគីណាមួយបានសុំកូនអ្នកដទៃមកចិញ្ចឹមបីបាច់ថែរក្សា។

## លេខយោងទំព័រទី១

ចុងទំព័រទី១ "*គូភាគីខាងលើបានបង្ហាញនូវឆន្ទៈរបស់ខ្លួនដោយសេរី និងពេញចិត្ត។ ភាគីទាំងពីរ ថានឹងទទួលខុសត្រូវចំពោះសេចក្តីថ្លែងរបស់ខ្លួនទាំងស្រុង។ សេចក្តីថ្លែងនេះមិនមែនជាទស្សនៈ និងការទទួលខុសត្រូវរបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជាឡើយ។ លិខិតនេះផ្តល់ឱ្យសាម៉ីខ្លួនយកទៅប្រើប្រាស់ទៅតាមលទ្ធភាពដែលអាចប្រើប្រាស់បាន។*

**<u>កថាខណ្ឌទី១</u>**៖ នេះគឺបញ្ជាក់ជាម្តងទៀតថា ភាគីដែលផ្តិតមេដៃលើសេចក្តីថ្លែងទំនាក់ទំនងគ្រួសារនេះគឺចេញពីឆន្ទៈ ភាពសុខចិត្ត និងពេញចិត្តរបស់ភាគីទាំងពីរ។

**<u>កថាខណ្ឌទី២</u>**៖ នេះជាការប្តេជ្ញាចិត្តផ្ទាល់របស់ភាគី ដែលទទួលស្គាល់សេចក្តីថ្លែងទំនាក់ទំនងគ្រួសារនេះថាជារបស់ខ្លួនពិតប្រាកដមែន ហើយទទួលខុសត្រូវចំពោះអំពើទាំងឡាយណាដែលអាចជាផលខូចខាតផ្ទុយពីឆន្ទៈបានចែងនៅក្នុងទម្រង់នេះ។ ឧទាហរណ៍៖ ភាគីមិនអាចលើកសំអាងថា ខ្លួនមិនយល់នូវអត្ថន័យទាំងស្រុងនៅក្នុងសេចក្តីថ្លែងទំនាក់ទំនងគ្រួសារនេះឡើយ។

**<u>កថាខណ្ឌទី៣</u>**៖ ក្នុងកថាខណ្ឌនេះ អង្គការសហគមន៍ឥន្ទធនូកម្ពុជាមិនមែនជាភាគីមួយនៃសេចក្តីថ្លែងនេះឡើយ។ ដូច្នេះ វាមិនមែនជាការទទួលខុសត្រូវរបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជាចំពោះការខូចខាតទាំងឡាយណាដែលកើតចេញពីសេចក្តីថ្លែងទំនាក់ទំនងគ្រួសារនេះទេ។ ទន្ទឹមនឹងនេះ អង្គការសហគមន៍ឥន្ទធនូកម្ពុជាក៏លើកកម្ពស់សិទ្ធិក្នុងការសម្រេចចិត្តរបស់ភាគីផងដែរ។

**<u>កថាខណ្ឌទី៤</u>**៖ ចំណុចនេះបញ្ជាក់ពីការព្រមព្រៀង ដោយគ្មានការបង្ខិតបង្ខំទៅលើគូភាគី សាក្សី និងអាជ្ញាធរមូលដ្ឋានឱ្យចុះសេចក្តីថ្លែងទំនាក់ទំនងគ្រួសារនេះឡើយ។ ដោយសារតែនៅប្រទេសកម្ពុជាមិនទាន់មានច្បាប់អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នា ហើយសេចក្តីថ្លែងទំនាក់ទំនងគ្រួសារក៏មិនមែនជាឯកសារគតិយុត្តរបស់រាជរដ្ឋាភិបាលដែរ។ ដូច្នេះការធ្វើសេចក្តីថ្លែងទំនាក់ទំនងគ្រួសារនេះគឺត្រូវឈរលើគោលការណ៍ស្ម័គ្រចិត្ត និងការប្តេជ្ញារបស់ភាគីឯកជន។ នេះមានន័យថាការប្រើប្រាស់សេចក្តីថ្លែងទំនាក់ទំនងគ្រួសារ គឺជាលទ្ធភាពរបស់អ្នកពាក់ព័ន្ធដែលយល់ច្បាស់នៃទម្រង់សេចក្តីថ្លែងទំនាក់ទំនងគ្រួសារ ហើយប្រើប្រាស់ទម្រង់នេះ ដើម្បីការពារឧត្តមប្រយោជន៍ផ្សេងៗរបស់គ្រួសារអ្នកស្រឡាញ់ភេទដូចគ្នា។

## ទំព័រទី២ នៃសេចក្ដីថ្លែងទំនាក់ទំនងគ្រួសារ

### 7. ការផ្តិតមេដៃ របស់ភាគី៖

- ភាគីត្រូវផ្តិតមេដៃស្តាំ ប្រសិនបើគ្មានមេដៃស្តាំទេ គឺត្រូវផ្តិតម្រាមដៃណាមួយ នៃភាគីនោះ។ ក្នុងករណី គូភាគីមានពិការភាពកាយសម្បទា (ពិការដៃទាំងសងខាង) គូភាគីអាចស្នើសុំសាក្សីជួយសរសេរបញ្ជាក់ត្រង់ចំណុចផ្តិតមេដៃអំពីស្ថានភាពពិការភាពនៃបុគ្គលនោះបាន។ *(ឧទាហរណ៍៖ ភាគី "ក" មិនមានប្រអប់ដៃទេ)*។
- គូភាគីត្រូវផ្តិតមេដៃរាល់ទម្រង់នៃសេចក្តីថ្លែងទំនាក់ទំនងគ្រួសារ។
- ទឹកពណ៌ដែលត្រូវផ្តិតមេដៃត្រូវប្រើពណ៌ខៀវ។
- ការសរសេរឈ្មោះ ត្រូវសរសេរពីខាងក្រោមស្នាមមេដៃ ។
- ចាំបាច់ណាស់ តម្រូវឱ្យគូភាគីដែលជាម្ចាស់សេចក្តីថ្លែងទំនាក់ទំនងគ្រួសារសរសេរដោយផ្ទាល់ដៃ។ ក្នុងករណីគូភាគីមិនចេះអក្សរ ពួកគាត់អាចស្នើសុំឱ្យសាក្សី ឬមេភូមិ ជួយបំពេញឱ្យបាន។

### 8 សាក្សី៖

- សូមអ្នកបំពេញឈ្មោះរបស់ភាគី នៅក្នុងចំណុចត្រេ។
- តាមអត្ថន័យក្នុងចំណារនេះ សាក្សីបានយល់ព្រមដោយស្ម័គ្រចិត្តថា ខ្លួនបានឃើញ និងដឹងឮថាភាគីទាំងពីរព្រមព្រៀងចំពោះមុខសាក្សីពិតប្រាកដមែន។
- ការផ្តិតមេដៃ គូភាគីត្រូវតែធ្វើនៅចំពោះមុខសាក្សី។
- ដូចគ្នានេះផងដែរ ការផ្តិតមេដៃប្រើប្រាស់ទឹកថ្នាំពណ៌ខៀវដូចគ្នានឹងចំណុច(ខ.១)ដែរ

*ចំណាំ៖ សូមជៀសវាងដាច់ខាតការផ្តិតមេដៃ ដែលមិនធ្វើនៅចំពោះមុខសាក្សី។ ដោយហេតុថាវាខុសនឹងចំណារពីខាងលើ ដែលថាសាក្សីបានឃើញ និងដឹងឮ។*




9.ហត្ថលេខារបស់អាជ្ញាធរមូលដ្ឋាន៖

ឃ្លាដែលត្រូវសរសេរ សម្រាប់មេភូមិ ៖

- អ្នកត្រូវបំពេញចំណុចគ្រេៗ នូវឈ្មោះរបស់ភាគី បន្ទាប់មកទៀតអ្នកត្រូវសរសេរនៅក្នុងចំនុចគ្រេៗថា *ពិតជាបានផ្តិតមេដៃ នៅចំពោះមុខយើងពិតប្រាកដមែន។*
- ភាគច្រើន មេភូមិមានត្រាឈ្មោះផ្ទាល់ខ្លួន ហេតុដូចនេះគាត់ត្រូវវាយត្រាឈ្មោះនោះ នៅខាងក្រោមហត្ថលេខារបស់ខ្លួន។

ឃ្លាដែលត្រូវសរសេរ សម្រាប់ប្រធានក្រុមប្រឹក្សាឃុំ /សង្កាត់ (គេច្រើនហៅ ថាមេឃុំៗ)

- អ្នកត្រូវបំពេញចំណុចគ្រេៗ ក្នុងបន្ទាត់ទី១ ដោយដាក់ឈ្មោះមេភូមិ។ បន្ទាប់មកទៀតត្រូវសរសេរថា *.....ពិតជាមេភូមិប្រាកដមែន.......* ។

- ក្រោយពីចុះហត្ថលេខាមេឃុំហើយ គាត់នឹងបោះត្រាប្រចាំឃុំ ដែលត្រានេះភាគច្រើនកាន់កាប់ដោយស្មៀនឃុំ ។

**លេខយោងទំព័រទី២**

នៅចុងទំព័រទី២ នៃសេចក្តីថ្លែងទំនាក់ទំនងគ្រួសារនេះ មានពីរកថាខណ្ឌបានសរសេរថា៖ “*យើងខ្ញុំទទួលស្គាល់ថាសេចក្តីថ្លែងទំនាក់ទំនងគ្រួសារនេះ គ្មានតម្លៃគតិយុត្តស្មើនឹងសំបុត្រអាពាហ៍ពិពាហ៍ទេ វាគ្រាន់តែជាសេចក្តីថ្លែងនៃការប្តេជ្ញារបស់យើងខ្ញុំទាំងពីរនាក់ប៉ុណ្ណោះ។ យើងខ្ញុំនឹងធ្វើការចុះសំបុត្រអាពាហ៍ពិពាហ៍ទៅតាមច្បាប់ នៅពេលដែលមានច្បាប់ចែងអំពីទំនាក់ទំនងគ្រួសារនៃអ្នកស្រឡាញ់ភេទដូចគ្នា។*"

<u>**កថាខណ្ឌទី១៖**</u> គឺមានន័យបញ្ជាក់ថា ប្រាប់ទាំងភាគីនៃទំនាក់ទំនងគ្រួសារ និងអាជ្ញាធរពាក់ព័ន្ធថា សេចក្តីថ្លែងទំនាក់គ្រួសារនេះ<u>មិនមែនជាសំបុត្រអាពាហ៍ពិពាហ៍ទេ</u> ដើម្បីកុំឱ្យអាជ្ញាធរ និងភាគីនៃកិច្ចសន្យាមានការយល់ច្រឡំថា ពួកគេកំពុងតែធ្វើសំបុត្រអាពាហ៍ពិពាហ៍។ កថាខណ្ឌនេះហើយ ដែលជាចំណុចបញ្ចុះបញ្ចូលយ៉ាងសំខាន់ក្នុងការធ្វើឱ្យ អាជ្ញាធរ និងសាក្សីទាំងឡាយមានការទុកចិត្ត ថាការចុះសេចក្តីថ្លែងទំនាក់ទំនងគ្រួសារ និងការធ្វើសាក្សីដឹងឮនៃឯកសារនេះ មិនមែនជាអំពើខុសច្បាប់ឡើយ។

<u>**កថាខណ្ឌទី២៖**</u> ឃ្លាដែលថា យើងខ្ញុំនឹងធ្វើការ<u>*ចុះសំបុត្រអាពាហ៍ពិពាហ៍ទៅតាមច្បាប់នេះ*</u> វាជាការបង្ហាញនូវចេតនារបស់ភាគីនៅចំពោះមុខសមត្ថកិច្ចថា ភាគីនៃទំនាក់ទំនងគ្រួសារនេះមានបំណងគោរពច្បាប់របស់ប្រទេស និងចង់ឱ្យរាជរដ្ឋាភិបាលយកចិត្តទុកដាក់អំពីស្ថានភាពគតិយុត្តរបស់អ្នកស្រឡាញ់ភេទដូចគ្នា។ នេះជាការបង្ហាញឱ្យឃើញថា ការរស់នៅនៃគ្រួសារអ្នកស្រឡាញ់ភេទដូចគ្នាត្រូវការការគាំទ្រផ្នែកច្បាប់ ហើយវាក៏ជាការទទួលខុសត្រូវរបស់ប្រទេសស្តីពីគតិយុត្តមួយ ដែលជានាការពារ ការទទួលខុសត្រូវនៃកាតព្វកិច្ច និងករណីយកិច្ចចំពោះគ្រួសារអ្នកស្រឡាញ់ភេទដូចគ្នា។ ដោយហេតុថាគ្រួសារអ្នកស្រឡាញ់ភេទដូចគ្នា គឺជាផ្នែកមួយនៃសង្គមជាតិផងដែរ។

# ៩.   ការរក្សាទុកទម្រង់សេចក្តីថ្លែងទំនាក់ទំនងគ្រួសារ

ក្រោយពេលដែលគូភាគីបានចុះរួចរាល់ហើយ គូភាគីគួរតែចម្លងទម្រង់សេចក្តីថ្លែងទំនាក់ទំនងគ្រួសារនេះទុកសម្រាប់ភាគីទាំងសងខាង និងរក្សាទុកនៅកន្លែងដែលខ្លួនយល់ថាមានសុវត្ថិភាព និងសន្តិសុខសម្រាប់ជាប្រយោជន៍របស់ក្រុមគ្រួសារ។ បន្ថែមទៅលើនោះ ដៃគូអាចផ្តល់ព័ត៌មានពីការចុះមកកាន់អង្គការសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់) សម្រាប់ការចងក្រងព័ត៌មាននៃសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាទូទាំងប្រទេស។ សូមបញ្ជាក់ថា វាមិនមែនជាកាតព្វកិច្ចដែលដៃគូត្រូវតែធ្វើនោះទេ ប៉ុន្តែវាជាការចូលរួមចំណែកលើកកម្ពស់ស្ថានភាពអ្នកស្រឡាញ់ភេទដូចគ្នាផងដែរ។ រាល់ព័ត៌មានដែលរ៉ក់ទទួលបាននៃការចុះនូវទម្រង់នេះ នឹងត្រូវរក្សាការសម្ងាត់។

## ក្បាលបញ្ជី

ដើម្បីជួយសម្រួលដល់ការរក្សាទុកទិន្នន័យ រាល់ទម្រង់សេចក្តីថ្លែងទំនាក់ទំនងគ្រួសារបានភ្ជាប់ជាមួយក្បាលបញ្ជីដែលមានលេខរៀង និងព័ត៌មានពីដៃគូដែលអ្នកសម្របសម្រួលមានដូចជាអាជ្ញាធរមូលដ្ឋាននិងសមាជិកសកម្មរ៉ក់ជាដើម ចូលរួមជួយបំពេញ និងរក្សាទុកផងដែរ។

## **អំពីអង្គការសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់)**

អង្គការសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់) គឺជាអង្គការមិនមែនរដ្ឋាភិបាលមួយដែលដឹកនាំដោយអ្នកស្រឡាញ់ភេទដូចគ្នា ធ្វើការគាំទ្រសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា និងមានទស្សនវិស័យចង់ឃើញអ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា អាចរស់នៅដោយទទួលបានការគោរព ការទទួលយកការពិត និងសិទ្ធិមនុស្សពេញលេញ និងស្មើភាពគ្នាលើគ្រប់វិស័យនៃសង្គម ជាពិសេសពីក្រុមគ្រួសារ សហគមន៍ និងអាជ្ញាធរ។ ពួកយើងប្រាថ្នាចង់ឃើញពលរដ្ឋកម្ពុជាដែលជាអ្នកស្រឡាញ់ភេទដូចគ្នា មានអារម្មណ៍សប្បាយរីករាយ រស់នៅជាខ្លួនឯង និងរស់នៅក្នុងជីវិតដ៏រីករាយ។

* * * * *

-វិដេអូពន្យល់បន្ថែមពីសេចក្តីថ្លែងទំនាក់ទំនងគ្រួសារ https://www.youtube.com/watch?v=p1TTptvx6lY

- ព័ត៌មានទំនាក់ទំនងមកកាន់សហគមន៍ឥន្ទធនូកម្ពុជា

  - លេខទូរសព្ទ ០១២ ៤៨១ ៥៦១ / ០៩០ ៨៧ ៥៩ ២៩
  - បណ្តាញសង្គមហ្វេសប៊ុក៖ @rockhmerlgbt2009
  - គេហទំព័រ៖ www.rockcambodia.org